ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១៥ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែមេសា ឆ្នាំ២០១៥

នាវេលាម៉ោង ០៨: ៣០ នាទីព្រឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែមេសា ឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នឹងមានការចូលរួមពីសំណាក់ឯកឧត្តម លោកស្រីអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។



ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានសំដែងអំណរសាទរជាមួយថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសម្រេចបានប្រចាំខែមេសា ឆ្នាំ២០១៥ និងជំរុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាកនិងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទ ឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ តាមរយៈការបង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ងាយស្រួល ឆាប់រហ័ស នៅគ្រប់ទីកន្លែង និងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៥។

ក្នុងខែមេសា ឆ្នាំ២០១៥នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៨១៧ ០០១ លានរៀល (គិតជាដុល្លារប្រមាណ ២០៤,២៥ លានដុល្លារ)។ ប្រសិនបើប្រៀបធៀបទៅនឹង

ចំណូលពន្ធប្រចាំខែមេសា ដូចគ្នាឆ្នាំ២០១៤ ឃើញថា ការប្រមូលចំណូលពន្ធដារបង់ចូលថវិកាជាតិប្រចាំខែមេសាឆ្នាំ២០១៥ នេះមានការកើនឡើងស្មើនឹង ៤០,៩១%។

ក្នុងរយៈពេលបួនខែដើមឆ្នាំ២០១៥ ចំណូលពន្ធ-អាករសរុបមានចំនួនស្មើនឹង ៤៥,៥១ % នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ក្នុងនោះមាន÷ថវិកាថ្នាក់ជាតិប្រមូលបានចំនួនស្មើនឹង ៤៧,២១% និងថវិកាថ្នាក់ក្រោមជាតិប្រមូលបានចំនួនស្មើនឹង ៣៤,៦២%។

ក្នុងរយៈពេលដូចគ្នាឆ្នាំ២០១៤ និងឆ្នាំ២០១៥ ឃើញថា ក៏មានការកើនឡើងនូវចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗមួយចំនួន ដូចជា ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ៥០,៤% ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ៣១,៦% អាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ៣៩,៧% និង អាករពិសេសមានការកើនឡើងប្រមាណ ៣០,៨%។

បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ២០១៤ និងឆ្នាំ២០១៥ ចំណូលពន្ធតាមសកម្មភាពអាជីវកម្មមានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន÷ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ ២២,៩% ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ៣៩,០% ផ្នែកទូរគមនាគមន៍កើនឡើងប្រមាណ ២៣,៣% ផ្នែកនីហរ័ណអាហរ័ណកើនឡើងប្រមាណ ១៧,១% ផ្នែកផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ៣,៩% ផ្នែកសណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ៤៤,៦% ផ្នែកផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ១១,៥% ផ្នែកផលិតថ្នាំជក់កើនឡើងប្រមាណ ៩៥,៤% ផ្នែកដឹកជញ្ជូននិងទេសចរណ៍កើនឡើងប្រមាណ ៧,២% ផ្នែកអាកាសយានដ្ឋាននិងកំពង់ផែកើនឡើងប្រមាណ ១១,៧% ផ្នែកលក់សម្ភារៈការិយាល័យកើនឡើងប្រមាណ ៥២,៧% ផ្នែកលក់ភេសជ្ជៈកើនឡើងប្រមាណ ៥២,២% ផ្នែកផលិតយានយន្តកើនឡើងប្រមាណ ១៨១,៥% ផ្នែកផលិតម្ហូបអាហារកើនឡើងប្រមាណ ២៦,០% និងផ្នែកផលិតគ្រឿងចក្រកើនឡើងប្រមាណ ៥៩,៧%។

ក្នុងអង្គប្រជុំឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា ១-ពិនិត្យនិងពិភាក្សាលើរបាយការណ៍លទ្ធផលប្រមូលចំណូលពន្ធប្រចាំខែមេសាឆ្នាំ២០១៥ របស់អង្គភាពនីមួយៗ។ ២-វឌ្ឍនភាពនៃការចាត់បញ្ចូលអាជីវកម្មដ្ឋានជាប់ពន្ធតាមរបបម៉ៅការទៅរបបស្វ័យប្រកាស។ ៣-ពិភាក្សាការដាក់លិខិតប្រកាសពន្ធ ការធ្វើសវនកម្មពន្ធ និងការគ្រប់គ្រងបំណុលពន្ធ។ ៤-ពិភាក្សាអំពីយន្តការនៃការបង្វិលសង។ ៥-ការត្រួតពិនិត្យការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ និងពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៥។ ៦-ការចុះបញ្ជីសហគ្រាសតាមប្រព័ន្ធថ្មីនិងការធ្វើបច្ចុប្បន្នភាពសហគ្រាស។ ៧-វឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) និងត្រួតពិនិត្យ ការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យមរបស់អគ្គនាយកដ្ឋានពន្ធដារឆ្នាំ២០១៤-២០១៨ (RMS)។ ៨-បញ្ហាផ្សេងៗ។

ដើម្បីប្រមូលចំណូលបានគ្រប់តាមផែនការច្បាប់ និងដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាសម្រាប់បម្រើឱ្យកិច្ចការគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនោះ ជាទិសដៅអនុវត្តបន្ត អគ្គនាយកដ្ឋានពន្ធដារនឹងបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយកែទម្រង់ដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងនោះ ÷

- បន្តពង្រឹងការប្រមូលពន្ធគ្រប់ប្រភេទ ជាពិសេស ពន្ធលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែម អាករពិសេសលើបារី និងស្រាបៀ
- បន្តពង្រឹងការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មីឱ្យកាន់តែប្រសើរឡើង និងកាន់តែមានប្រសិទ្ធភាពខ្ពស់ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ ក៏ដូចជាយន្តការនៃការគ្រប់គ្រងការរៀបចំទុកដាក់ឯកសារ
- បន្តពង្រឹងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសទាំងអស់ ដែលបានចុះបញ្ជីពន្ធដារដាក់ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធ
- ធ្វើបច្ចុប្បន្នភាពទិន្នន័យអចលនទ្រព្យទាំងអស់ដែលបានចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ដាក់ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) របស់អគ្គនាយកដ្ឋានពន្ធដារ

- បន្តលើកកម្ពស់និងបញ្ជ្រាបវប្បធម៌ពន្ធដារ បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសារពើពន្ធ ក្នុងចំណោមធុរជនគ្រប់មជ្ឈដ្ឋាន តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីប្រព័ន្ធពន្ធដារកម្ពុជា។




ជាកិច្ចបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់និងមន្ត្រីពន្ធដារទាំងអស់ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ គោរពវិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសម្រេចបានតាមផែនការក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**អគ្គនាយកដ្ឋានពន្ធដារ**